**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :.១០៤..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ សំរាប់ប្រើប្រាស់ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : សញ្ញារបស់ក្រសួងមហាផ្ទៃ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ត្រូវបានកំណត់ដូចតទៅនេះ ÷

- រូបព្រះនារាយណ៍មានដៃបួន ដៃស្តាំខាងលើកាន់ខ្យងស័ង្ខ ដៃស្តាំខាងក្រោមកាន់សៀវភៅ ដៃឆ្វេងខាងលើកាន់កងចក្រ ដៃឆ្វេងខាងក្រោមកាន់ព្រះខ័ន តំណាងអោយភាវៈល្អ រក្សា ការពារ កសាង
- មានពណ៌មាស
- មានទទឹង ២ ភាគ ៣ នៃបណ្តោយ
- ពន្លឺករស្មី តំណាងអោយគំនិត ប្រាជ្ញា ស្មារតី
- កងចក្រ ព្រះខ័ន តំណាងអោយសិទ្ធិ អំណាច តួនាទី
- សៀវភៅ តំណាងអោយច្បាប់ លិខិតបទដ្ឋាន
- ខ្យងស័ង្ខ តំណាងអោយភាពត្រជាក់ត្រជុំ សេចក្តីសុខក្សេមក្សាន្ត សុភមង្គល
- ក្បាច់ភ្ញីភ្លើង តំណាងអោយភាពអង់អាចក្លាហាន
- បល្ល័ង្គ តំណាងអោយព្រះធរណី អាជ្ញាធរដែនដី នគរបាលជាតិ

- ភ្ជាប់ចំរុះ តំណាងអោយអរិយធម៌ វប្បធម៌ ភាពថ្កុំថ្កើងរុងរឿង ។

**មាត្រា ៣** : សញ្ញារបស់ក្រសួងមហាផ្ទៃ សំរាប់ប្រើប្រាស់ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោមនេះ ÷

- ធ្វើត្រា
- ដាក់នៅកន្លែងធ្វើការ
- ធ្វើប្រទីប
- ពាក់នៅលើឯកសណ្ឋានរបស់មន្ត្រីរាជការក្របខ័ណ្ឌរបស់ក្រសួងមហាផ្ទៃ
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រសួងមហាផ្ទៃ
- ប្រើប្រាស់ជាផ្លូវការសំរាប់ក្រសួងមហាផ្ទៃ ក្នុងករណីផ្សេងៗទៀត ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត- ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១*

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ- កាលប្បវត្តិ*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១**
**ស្ដីពីសញ្ញាក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**



# សញ្ញាក្រសួងមហាផ្ទៃ